Vision: A democratic society that democratization in particular democratic elections are promoted and qualified to bring benefits to people.
ទស្សនៈវិស័យ ៖ ដើម្បីឲ្យការបោះឆ្នោតមានគុណភាព ដែលប្រកបដោយលក្ខណៈប្រជាធិបតេយ្យ

ភ្នំពេញ, ថ្ងៃទី២២ ខែមករា ឆ្នាំ២០១៣

# លទ្ធផលវេទិកា នៅខេត្តកំពង់ធំ
# "កំណែទម្រង់ការបោះឆ្នោត និងលំហរប្រជាធិបតេយ្យនៅកម្ពុជា"

គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល) ក្រោមកិច្ចសហការជាមួយបណ្តាអង្គការ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន បានរៀបចំវេទិកាមួយ ស្តីអំពី "**កំណែទម្រង់ការបោះឆ្នោត និងលំហរប្រជាធិបតេយ្យនៅកម្ពុជា (FOREDS)**" នៅ **ខេត្តកំពង់ធំ** កាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៣ ដោយមានការចូលរួមពីតំណាងគណបក្សនយោបាយ តំណាងគ.ជ.បខេត្ត អាជ្ញាធរមូលដ្ឋាន ប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលដែលពាក់ព័ន្ធប្រមាណ **៨៩នាក់**។

វេទិកានេះរៀបចំឡើងក្នុងគោលបំណង ដើម្បីឲ្យភាគីដែលពាក់ព័ន្ធបានលើកឡើង និងជជែកពីបញ្ហាដែលទាក់ទងទៅនឹងការបោះឆ្នោត និងប្រជាធិបតេយ្យនៅកម្ពុជា ហើយស្វែងរកនូវអនុសាសន៍ គោលនយោបាយដែលបានពិភាក្សាចែកជូនដល់អ្នកចូលរួម និងបញ្ជូនអនុសាសន៍ទាំងនោះទៅស្ថាប័នដែលពាក់ព័ន្ធក្នុងការដោះស្រាយ។

| **អនុសាសន៍ពី វេទិកា FOREDS នៅខេត្តកំពង់ធំ (ថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៣)** |
|---|
| **១. ការជ្រើសរើស និងការពង្រឹងសមត្ថភាពមន្ត្រីបោះឆ្នោតនៅថ្នាក់ឃុំ និងថ្នាក់ការិយាល័យបោះឆ្នោត**<br>**ក.** មន្ត្រីថ្នាក់ឃុំ៖<br>▪ ជ្រើសរើសមន្ត្រីដែលមានទីលំនៅក្នុងឃុំ-សង្កាត់នោះ (៥នាក់)<br>▪ ការផ្សព្វផ្សាយជ្រើសរើសមន្ត្រីឃុំមានរយៈពេលវែង និងទូលំទូលាយ តាមរយៈទូរទស្សន៍ វិទ្យុ ឧឃោសនស័ព្ទ<br>▪ មិនគួរជ្រើសរើសអ្នកដែលមានការងារច្រើន<br>▪ ចំពោះឃុំដែលមានការិយាល័យបោះឆ្នោតច្រើន សុំបង្កើនចំនួនសមាជិក គ.ឃ.ប<br>▪ មន្ត្រី គ.ឃ.ប មានកិច្ចសហការល្អជាមួយក្រុមប្រឹក្សាឃុំ អាជ្ញាធរ និងគណបក្សនយោបាយដោយមិនមានការរើសអើង<br>▪ ការជ្រើសរើសមន្ត្រី CEC គួរឲ្យមានតម្លាភាព និងយុត្តិធម៌ (ជៀសវាងសាច់ញាតិ និងបក្សពួក និងសុំឲ្យយកមន្ត្រីចូលនិវត្តន៍ និងយុវជន)<br>**ខ.** មន្ត្រីការិយាល័យបោះឆ្នោត៖<br>▪ ជ្រើសរើសអ្នកមានសមត្ថភាពការងារ សីលធម៌ ឆន្ទៈការងារ |

- អ្នកមានទីលំនៅជិតការិយាល័យបោះឆ្នោត
- សុំឲ្យមានការបណ្ដុះបណ្ដាលរយៈពេលវែង (រយៈពេល៣ថ្ងៃ ទៅ៧ថ្ងៃ)
- ការផ្សព្វផ្សាយឲ្យបានទូលំទូលាយ
- បន្ថែមថវិកាដល់មន្ត្រី គ.ឃ.ប និងមន្ត្រីការិយាល័យ

**២. ការទប់ស្កាត់ និងបង្ការអំពើហិង្សាពេលបោះឆ្នោត**

- នគរបាល មន្ត្រីប៉ុស្តិ៍រដ្ឋបាល កុំរើសអើងគណបក្សនយោបាយ
- សុំអាជ្ញាធរគោរពច្បាប់បោះឆ្នោត (កុំឲ្យមានការគំរាមកំហែង កុំប្រើកំលាំងអំពើហិង្សា បំភិតបំភ័យ)
- កុំញុះញ៉ង់អ្នកគាំទ្រទៅលើបេក្ខជន និងគណបក្សនយោបាយ
- គ.ឃ.ប  កុំប្រើពាក្យសម្ដីអសីលធម៌មកលើគណបក្ស និងប្រជាពលរដ្ឋ
- គ.ក.ប កុំប្រើពាក្យសម្ដីអសីលធម៌លើប្រជាពលរដ្ឋ
- គណបក្សនយោបាយនីមួយៗត្រូវតែគោរពតាមប្រតិទិន និងទីកន្លែងដែលត្រូវឃោសនា
- កុំប្រើគ្រឿងស្រវឹង នៅពេលបោះឆ្នោត (គ្រប់អ្នកពាក់ព័ន្ធទាំងអស់ និងអ្នកលក់គ្រឿងស្រវឹង) កំឡុងពេលចាប់ពីការចាប់ផ្ដើមឃោសនាបោះឆ្នោតដល់ពេលបោះឆ្នោតរួច
- នៅថ្ងៃបោះឆ្នោតសូមកុំឲ្យអាជ្ញាធរដែនដី (មេឃុំ ក្រុមប្រឹក្សាឃុំ ប្រធានភូមិ អនុប្រធានភូមិ និងក្រុមការងាររបស់គណបក្សនយោបាយ) ទៅឈរនៅក្នុងបរិវេណមណ្ឌលបោះឆ្នោត នៅគ្រប់ការបោះឆ្នោតទាំងអស់

**៣. ដំណោះស្រាយបណ្ដឹងទាក់ទងនៅនឹងការបោះឆ្នោត**

**ក.** គួរតែបង្កើតស្ថាប័នឯករាជ្យមួយផ្សេងទៀត ដាច់ដោយឡែកពី គ.ជ.ប

**ខ.** សមាសភាពក្នុងស្ថាប័នរួមមាន៖

- តំណាងសង្គមស៊ីវិល ចំនួនពីររូប
- តំណាងរដ្ឋាភិបាល ចំនួនមួយរូប
- តំណាងរដ្ឋសភា ចំនួនមួយរូប
- គណបក្សនយោបាយនីមួយៗដែលមានអាសនៈនៅក្នុងរដ្ឋសភា ត្រូវមានតំណាងមួយរូប

**គ.** លក្ខណៈសម្បត្តិរបស់សមាសភាព

- មានសញ្ញាប័ត្រចាប់ពីបរិញ្ញាប័ត្រឡើងទៅ (ខាងច្បាប់)
- មានកាយសម្បទាគ្រប់គ្រាន់
- មានជំហរអព្យាក្រិត្យ

**ឃ.** ស្ថាប័នត្រូវមានចែងក្នុងរដ្ឋធម្មនុញ្ញ

**៤. សេរីភាពក្នុងការបញ្ចេញមតិ និងប្រមូលផ្ដុំ**

- សំណូមពរដល់រដ្ឋាភិបាល និងរដ្ឋសភាអនុញ្ញាតច្បាប់ឲ្យគ្រប់គណបក្សនយោបាយបង្កើត ប៉ុស្តិ៍វិទ្យុពិសេសទូរទស្សន៍ ឲ្យបានទូលំទូលាយ
- រាល់សេរីភាពក្នុងការបញ្ចេញមតិ ត្រូវគោរពទៅតាមគោលការណ៍ច្បាប់
- រាល់លិខិតបទដ្ឋាន និងច្បាប់ផ្សេងៗ ដែលសភាបានអនុម័ត គឺត្រូវផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឲ្យបានទូលំទូលាយ។

- រាល់ការអញ្ជើញប្រជាពលរដ្ឋមកប្រជុំ សូមកុំឲ្យមេភូមិមានការរើសអើង
- រដ្ឋាភិបាលបើកទូលាយពីសេរីភាពអ្នកប្រមូលផ្តុំធ្វើបាតុកម្មដោយមិនកំណត់មនុស្ស និងទីកន្លែង

**៥. ហិរញ្ញវត្ថុគណបក្សនយោបាយ**

**បញ្ហា៖**

- យកលុយទៅទិញសន្លឹកឆ្នោត
- សូកប៉ាន់មន្ត្រីគណបក្ស សកម្មជន
- ការចំណាយមិនតុល្យភាពរវាងគណបក្ស

**អនុសាសន៍៖**

- កំណត់ចំនួនអតិបរមានៃការចំណាយនៅក្នុងពេលយុទ្ធនាការឃោសនាបោះឆ្នោតនីមួយៗ
- រដ្ឋត្រូវតែផ្តល់ថវិការដ្ឋមួយចំនួនដើម្បីជួយគណបក្សនយោបាយសម្រាប់ឃោសនា
- បង្កើតគណកម្មការឯករាជ្យដើម្បីត្រួតពិនិត្យការចំណាយ និងចំណូលរបស់គណបក្សនយោបាយ
- ត្រូវបង្ហាញរបាយការណ៍លំអិត ស្តីពីប្រភពចំណូល ចំណាយ របស់គណបក្សនយោបាយ ជាសាធារណៈ
- គ.ជ.ប ត្រូវផ្សព្វផ្សាយឲ្យប្រជាពលរដ្ឋយល់ដឹងអំពីផលវិបាកនៃការទិញដូរសន្លឹកឆ្នោត និងលើកទឹកចិត្តឲ្យប្រជាពលរដ្ឋចូលរួមជួយទប់ស្កាត់
- គ.ជ.ប ត្រូវត្រួតពិនិត្យការរំលោភបំពានធនធានរដ្ឋដោយគណបក្សនយោបាយនៅពេលឃោសនាបោះឆ្នោត

*សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង ៖*

*១-លោក **សួន យុត្បា** / មន្ត្រីតស៊ូមតិ និងច្បាប់ខុមហ្វ្រែល (០៩៧-៥៩-៨៧-២៦៥)*

***បេសកម្ម*** *៖* បេសកកម្មរបស់ខុមហ្វ្រែល គឺជួយបង្កើតបរិយាកាសគួរជាទីពេញចិត្ត និងមានព័ត៌មានគ្រប់គ្រាន់ ទី១/**ដើម្បីឱ្យមានដំណើរការបោះឆ្នោតដោយសេរី និងយុត្តិធម៌** តាមរយៈការបញ្ចុះបញ្ចូល តស៊ូមតិ ដើម្បីទទួលបាននូវក្របខ័ណ្ឌច្បាប់សមរម្យ, ការអប់រំដើម្បីផ្តល់ព័ត៌មានដល់អ្នកបោះឆ្នោត អំពីសិទ្ធិ និងសកម្មភាពចូលរួមសង្កេតការណ៍របស់ពួកគេ ដែលអាចរារាំងនូវភាពមិនប្រក្រតី ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឲ្យមានការវាយតម្លៃលើដំណើរការបោះឆ្នោតមួយដែលមិនលំអៀង និងមិនប្រកាន់បក្សពួក ទី២/ **ដើម្បីឱ្យមានអត្ថន័យនៃដំណាក់កាលក្រោយពេលបោះឆ្នោត** តាមរយៈការអប់រំ និងវេទិកាសាធារណៈក្នុងគោលបំណងជំរុញលើកទឹកចិត្តប្រជាពលរដ្ឋឱ្យចូលរួមក្នុងកិច្ចការនយោបាយ និងការធ្វើសេចក្តីសំរេចនានា ការតស៊ូមតិ/បញ្ចុះបញ្ចូលដើម្បីឱ្យមានការកែទម្រង់ដំណើរការបោះឆ្នោតដែលបង្កើននូវគណនេយ្យភាព (ការទទួលខុសត្រូវ) របស់មន្ត្រីជាប់ឆ្នោត ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឱ្យមានការវាយតម្លៃមួយដែលមិនលំអៀង និងប្រកាន់បក្សពួកទៅលើការបំពេញកម្មវិធីនយោបាយ និងដំណើរការអនុវត្តន៍ ការងាររបស់មន្ត្រីជាប់ឆ្នោត។